01376736

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 01 / 2017
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E456

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧

**ជូនចំពោះ៖** ឯ.ឧ ក្រាញ់ តូនី ប្រធានស្តីទីនៃការិយាល័យរដ្ឋបាល

លោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និង ប្រធានអង្គភាពគាំពារការការពារក្តី

**កម្មវត្ថុ៖** គម្រោងកាត់ថវិកាសម្រាប់ក្រុមមេធាវីការពារក្តី

១. នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សារណាផ្ទាល់មាត់របស់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ស្តីពីគម្រោងកាត់ថវិកាសម្រាប់ក្រុមមេធាវីការពារក្តី នៅក្នុងសំណុំរឿង ០០២/០២។ ក្រុមមេធាវីការពារក្តីទាំងពីរ បានលើកឡើងនូវការព្រួយបារម្ភអំពីផលប៉ះពាល់នៃគម្រោងកាត់ថវិកា ដែលនឹងអាចបណ្តាលឱ្យមានការកាត់បន្ថយបុគ្គលិក និងផលលំបាកយ៉ាងធ្ងន់ធ្ងរដល់ការរៀបចំសារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សររបស់ខ្លួន ដែលត្រូវបានកំណត់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧ និងសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលនឹងចាប់ផ្តើមធ្វើនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧។

មេធាវីការពារក្តី នួន ជា មានគម្រោងស្នើសុំពន្យារពេលកំណត់ក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ប្រសិនបើគម្រោងកាត់ថវិកាអនុវត្តធ្វើមុនកាលបរិច្ឆេទកំណត់ទាំងនេះ។ ក្រុមមេធាវីការពារក្តី បានស្នើសុំការគាំទ្រពីអង្គជំនុំជម្រះសាលាដំបូង លើការពន្យារពេលនៃការកាត់គម្រោងថវិកា រហូតដល់កាលបរិច្ឆេទកំណត់នៃការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ ចំពោះសារណាផ្ទាល់មាត់ពេញលេញរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងបញ្ហានេះ សូមមើលសេចក្តីព្រាងប្រតិចារឹកសវនាការ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧។

២. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយយកចិត្តទុកដាក់ លើសារណារបស់ក្រុមមេធាវីការពារក្តីនិងផលប៉ះពាល់ ដែលអាចមានលើការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ។ អង្គជំនុំជម្រះសាលាដំបូងគាំទ្រលើការស្នើសុំពន្យារពេលនៃគម្រោងកាត់ថវិកាសម្រាប់ក្រុមមេធាវីការពារក្តី យ៉ាងហោចណាស់រហូតដល់ដំណាច់ខែឧសភា ឆ្នាំ ២០១៧ និងប្រសើរជាងនេះទៅទៀត គឺពន្យារពេលរហូតដល់ពេលបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល។ ចៅក្រមនៃអង្គជំនុំជម្រះស្នើការិយាល័យរដ្ឋបាល ផ្តល់នូវព័ត៌មានអំពីស្ថានភាពពាក់ព័ន្ធនឹងគម្រោងកាត់ថវិកាសម្រាប់ក្រុមមេធាវីការពារក្តី នៅក្នុងសំណុំរឿង ០០២/០២ មកឱ្យអង្គជំនុំជម្រះសាលាដំបូង ឲ្យបានឆាប់រហ័ស។